ក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ
Transitional Democratic Council
ឯករាជ្យ សេរីភាព សមភាព

# សេចក្តីថ្លែងការណ៍

ការបោះឆ្នោតថ្នាក់ជាតិនៅប្រទេសកម្ពុជាកាលពីថ្ងៃទី ២៩ ខែកក្កា ឆ្នាំ២០១៨ បានធ្វើឡើងនៅក្នុងស្ថានភាពរឹករវដោយការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងគោលការណ៍ប្រជាធិបតេយ្យជាមូលដ្ឋានដែលបានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពប៉ារីស ២៣តុលា ១៩៩១។ គណបក្សប្រជាជនដែលក្តាប់អំណាចគ្រប់យ៉ាងក្នុងដៃបានប្រើប្រាស់គ្រប់មធ្យោបាយ ទាំងធនធានមនុស្ស យោធា និងហិរញ្ញវត្ថុដើម្បីជម្រុញការបោះឆ្នោតក្លែងក្លាយមួយប្រឆាំងនឹងឆន្ទៈរបស់ពលរដ្ឋខ្មែរ។ អ្នកបោះឆ្នោតត្រូវបានគេបង្ខំឱ្យទៅបោះឆ្នោតឱ្យគណបក្សប្រជាជនប្រឆាំងនឹងឆន្ទៈរបស់ពួកគេក្រោមការគំរាមកំហែង បំភិតបំភ័យ និងការសងសឹក។ ដោយសារការ បង្ខិតបង្ខំ គំរាមកំហែង បំភិតបំភ័យនេះ ធ្វើអោយមានពលរដ្ឋបានចេញទៅបោះឆ្នោតដ៏ច្រើនលើសលប់ហួសបរិមាណកាលពី ឆ្នាំ២០១៣ ដែលមានការចូលរួមដោយបក្សសង្គ្រោះជាតិ ដែលត្រូវបានអនុញ្ញាតអោយចូលរួមដោយគណបក្សប្រជាជន។

តាមការស្រាវជ្រាវរបស់អ្នកជំនាញនយោបាយនៃកម្ពុជាបានបង្ហាញថា ក្រោយឆ្នាំ១៩៩៣ ជាពិសេសក្រោយការចាកចេញដោយបង្ខំនៃអ៊ុនតាក់ពីកម្ពុជាក្រោយឆ្នាំ១៩៩៤ ការបោះឆ្នោតនៅកម្ពុជាសុទ្ធតែជាការបោះឆ្នោតក្លែងក្លាយដែលបានរំលោភសិទ្ធិមនុស្សនិង គោលការណ៍ប្រជាធិបតេយ្យជាមូលដ្ឋានដោយមានការចូលរួមយ៉ាងសកម្មពីគណបក្សប្រឆាំង និងការគាំទ្រមិនអាចប្រកែកបានពីសហគមន៍អន្តរជាតិដើម្បីធានាអំណាចរបស់លោកហ៊ុនសែន។ ប៉ុន្តែការបោះឆ្នោតជាតិនៅថ្ងៃទី២៩ ខែកក្កា ឆ្នាំ២០១៨កន្លងទៅនេះ បានបង្ហាញយ៉ាងច្បាស់ថា គណបក្សប្រជាជនក្តាប់អំណាចដ៏ផ្តាច់ការដាច់ខាតមួយដែលមិនអាចអោយដំណើរការគោរពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យប្រព្រឹត្តិទៅបានទេ។

ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅថ្ងៃទី២៣តុលា១៩៩១ នយោបាយអាណានិគមនិយមន៍និងប្រល័យពូជសាសន៍ស្ងប់ស្ងាត់មួយត្រូវបានរៀបចំឡើងប្រឆាំងនឹងពលរដ្ឋខ្មែរ។ យោងតាមរបាយការណ៍របស់អ្នកជំនាញសេដ្ឋកិច្ចនិងសង្គមដូចជា លោកកែមឡី បានបង្ហាញថា ៨០%នៃពលរដ្ឋខ្មែររស់បាននៅជុំវិញបន្ទាត់ក្រីក្រ ខណៈពេលដែលសម្បត្តិជាតិ ធនធានធម្មជាតិ និងសេដ្ឋកិច្ចគ្រប់យ៉ាងនៃប្រទេសកម្ពុជាត្រូវបានទន្ទ្រានប្លន់ដោយក្រុមហ៊ុនរដ្ឋាភិបាលនិងយោធាយួននិងចិន និងពួកកាន់អំណាចមួយក្តាប់តូចដែលបំរើនយោបាយអាណានិគមន៍ចិននិងយួន។ បច្ចុប្បន្នការប្រជែងប្លន់ធនធាន ទឹកដី និងសេដ្ឋកិច្ចខ្មែររវាងចិន និង យួនកំពុងតែរុញច្រានកម្ពុជាក្នុងភ្នក់ភ្លើងសង្គ្រាមមួយដែលអាចបង្កវិនាសកម្មដល់ពលរដ្ឋខ្មែរដូចកាលពីសម័យវាលពិឃាតម្តងទៀត។

ក.អ.ប សូមស្វាគមន៍ចំពោះវិធានការនានាដែលបានធ្វើឡើងដោយសហភាពអឺរ៉ុបកាលពីថ្ងៃទី១៣កញ្ញា២០១៨ បន្ទាប់ពីមានការបោះឆ្នោតក្លែងក្លាយនៅកម្ពុជា។ លើសពីកាយវិការជានិមិត្តរូបទាំងនេះ ក.អ.ប ជម្រុញឱ្យប្រទេសហត្ថលេខីនៅទីក្រុងប៉ារីសដើម្បីគោរព កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣តុលា១៩៩១ ដើម្បីស្វែងរកដំណោះស្រាយសមរម្យដើម្បីបញ្ចប់ឧក្រិដ្ឋកម្មយង់ឃ្នងនៅកម្ពុជា។ ក.អ.ប មានការសោកស្តាយចំពោះជំហររបស់ប្រទេសបារាំងនិងប្រទេសអាល្លឺម៉ង់ចំពោះរបបលោកហ៊ុនសែន ដែលជាការប្រមាថ និងបន្ថោកតម្លៃប្រទេសលទ្ធិប្រជាធិបតេយ្យនិងគោរពសិទ្ធិមនុស្ស។

ភ្នំពេញថ្ងៃទី ២៧ កញ្ញា ឆ្នាំ ២០១៨
ក្រុមប្រឹក្សាអន្តរកាលប្រជាធិបតេយ្យ